ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានរតនាគារជាតិ
នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ

**សូមគោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

## I-លទ្ធផលការងារដែលបានអនុវត្តក្នុងឆ្នាំ២០២០៖

អគ្គនាយកដ្ឋានរតនាគារជាតិបានអនុវត្តការងារក្នុងឆ្នាំ២០២០ មួយចំនួនដូចខាងក្រោម÷

១-បានជំរុញលើការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ របបសន្តិសុខសង្គមរបស់និវត្តជន (បជស) និងបេឡាជាតិអតីតយុទ្ធជន (បជអ) ពីរសប្តាហ៍ម្តងក្នុងមួយខែបានទាន់ពេលវេលា។

២-បានបន្តសហការជាមួយក្រសួង ស្ថាប័នថវិកាកម្មវិធី ក្នុងការដោះស្រាយបញ្ហាប្រឈម ដែលពាក់ព័ន្ធនឹងការអនុវត្តចំណាយថវិកា ជាពិសេសលើការអនុវត្តចំណាយរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធី។

៣-បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីអនុវត្តថវិកាសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

៤-បន្តបំប៉នសមត្ថភាពការងាររបស់មន្ត្រីជំនាញលើការត្រួតពិនិត្យ ការអនុវត្តចំណាយថវិកា ឱ្យបានត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ និងស្របតាមបច្ចុប្បន្នភាពនៃលិខិតបទដ្ឋានគតិយុត្តិ ព្រមទាំងបន្តពង្រឹងការតាមដានវឌ្ឍនភាពការងារជាប្រចាំ។

៥-បានបន្តសហការជាមួយក្រុមការងារ ITD ដើម្បីរៀបចំរបាយការណ៍ចំណាយថវិកា ចេញពីប្រព័ន្ធ FMIS ឱ្យបានត្រឹមត្រូវ ជាពិសេសរបាយការណ៍ចំណាយថវិកា សម្រាប់បម្រើដល់ការរៀបចំសេចក្តីព្រាងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ។

៦-បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ លើសេចក្តីព្រាងបឋមរបាយការណ៍វាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុថ្នាក់ជាតិឆ្នាំ២០២០។

៧-បានចូលរួមសិក្ខាសាលាពីចម្ងាយ (Webinar) ស្តីពីការរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដារគណនេយ្យសាធារណៈអន្តរជាតិផ្អែកលើមូលដ្ឋានសាច់ប្រាក់ (IPSAS Cash Basis Reporting)។

៨-បានចាត់បញ្ជូនគ្រូឧទ្ទេសចូលរួមធ្វើបទបង្ហាញ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានជូនក្រសួងស្ថាប័ន។

៩-បានចាត់មន្ត្រីឱ្យចូលរួមកម្មវិធីបណ្តុះបណ្តាលពីចម្ងាយស្តីពី "ស្ថិតិចំណាយរដ្ឋាភិបាលតាមចំណាត់ថ្នាក់មុខងារ"។

១០-បានចូលរួមកិច្ចប្រជុំលើតារាងសង្ខេបអំពីគម្រោងវិនិយោគសាធារណៈ ដែលត្រូវបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ។

១១-បានចាត់មន្ត្រីឱ្យចូលរួមសិក្ខាសាលាពិគ្រោះយោបល់ និងប្រមូលធាតុចូលសម្រាប់រៀបចំស្ថិតិចំណាយតាមចំណាត់ថ្នាក់មុខងារ ក្នុងប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS)។

១២-ចូលរួមរៀបចំប្រកាសលេខ៦៦៣សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

១៣-បានសម្របសម្រួលរៀបចំសិក្ខាសាលាផ្សព្វផ្សាយប្រកាស លេខ៦៦៣សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ ជូនដល់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ព្រមទាំងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគាររាជធានី ខេត្ត តាមរយៈប្រព័ន្ធ Online ដោយមានសិក្ខាកាមចូលរួមសរុបប្រមាណ៧៥០នាក់។

១៤-ចូលរួមរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដាគណនេយ្យសាធារណៈអន្តរជាតិ (IPSAS) សម្រាប់ឆ្នាំ២០១៩។

១៥-ចូលរួមរៀបចំសេចក្តីព្រាងប្រកាស ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំ កិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង។

១៦-ចូលរួមរៀបចំសេចក្តីណែនាំលេខ០០៩ សហវ ស្តីពីការអនុវត្តនីតិវិធីថ្មីសម្រាប់ការបើកផ្តល់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិកផ្សេងៗ ដែលមានគោលរបបកំណត់ច្បាស់លាស់ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។

១៧-ចូលរួមរៀបចំសេចក្តីណែនាំលេខ០១៥សហវ ស្តីពីការអនុវត្តនីតិវិធីថ្មីសម្រាប់ការចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាប សម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។

១៨-ចូលរួមរៀបចំសេចក្តីណែនាំលេខ ០១៣ សហវ ស្តីពីការអនុវត្តនីតិវិធីថ្មី សម្រាប់ការបើកផ្តល់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិកផ្សេងៗដែលមានគោលរបបកំណត់ច្បាស់លាស់ ក្នុងក្របខណ្ឌក្រសួង-ស្ថាប័នចំនួន០៧ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។

១៩-ចូលរួមរៀបចំសេចក្តីណែនាំលេខ០១៩ សហវ ស្តីពីការអនុវត្តនីតិវិធីថ្មីសម្រាប់ការចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាប សម្រាប់ក្រសួងចំនួន០៧ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។

២០-ចូលរួមប្រជុំពិភាក្សាលើរៀបចំសេចក្តីព្រាងនៃច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី និងសេចក្តីព្រាងនៃអនុក្រឹត្យលេខ៨១- ៨២ ថ្មី។

២១-បានរៀបចំកិច្ចប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

២២-បានបន្តប្ចូកសរុបនិងផ្ទៀងផ្ទាត់តួលេខចំណាយថវិកា ជាមួយក្រសួង ស្ថាប័ន ដើម្បីបិទបញ្ជីចំណាយឆ្នាំ២០១៩។

២៣-បានសហការជាមួយអាជ្ញាធរសវនកម្មជាតិ និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការធ្វើសវនកម្មលើការអនុវត្តច្បាប់ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។

២៤-បានចូលរួមរៀបចំតារាងឧបសម្ព័ន្ធ និងឯកសារពាក់ព័ន្ធនៃសេចក្តីព្រាងច្បាប់ទូទាត់ថវិកាឆ្នាំ២០១៩ ព្រមទាំងបានសម្របសម្រួលការងារពាក់ព័ន្ធនឹងការរៀបចំសេចក្តីព្រាងច្បាប់ទូទាត់ថវិកាថវិកាឆ្នាំ២០១៩។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានព្រឹទ្ធសភា ពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់ នាថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ ហើយត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខា នាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០។

២៥-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ និងផ្តល់យោបល់លើសេចក្តីព្រាងលើគោលការណ៍ណែនាំរួម ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ហៅកាត់ គ.គ.ហ (PFMM)។

២៦-បានចូលរួមប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីប្រាក់បេសកកម្ម, សេចក្តីព្រាងប្រកាសស្តីពីវិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងសេចក្តីព្រាងប្រកាសស្តីពីវិធាននិងនីតិវិធីចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

២៧-បានចុះសិក្សាអំពីតម្រូវការរៀបចំលំហូរការងារ (Business Process) នៃការបង់ចំណូលពីផលទុននៃទ្រព្យសម្បត្តិរដ្ឋ (សម្បទានដីសេដ្ឋកិច្ច) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបានរៀបចំលិខិតលេខ៧៩៧០សហវ អរតន ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការកត់ត្រាចំណូលដីសប្បទានសេដ្ឋកិច្ចក្នុងប្រព័ន្ធ NRMIS ជូនក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ។

២៨-បានចុះសិក្សាអំពីតម្រូវការរៀបចំលំហូរការងារ (Business Process) នៃការបង់ចំណូលពីផលទុននៃទ្រព្យសម្បត្តិរដ្ឋ (សម្បទានរ៉ែ) របស់ក្រសួងរ៉ែនិងថាមពល និងបានរៀបចំលិខិតលេខ៨៥៨០ សហវ អរតនចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ស្តីពីការកត់ត្រាចំណូលពីសប្បទានរ៉ែក្នុងប្រព័ន្ធNRMIS ជូនក្រសួងរ៉ែនិងថាមពល។

២៩-បានចូលរួមប្រជុំនិងផ្តល់យោបល់លើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន និងទម្រង់រូបិយ។

៣០-បានរៀបចំអនុស្សរណៈនៃការយោគយល់គ្នា (MoU) ស្តីពីការបង់ចំណូលមិនមែនសារពើពន្ធ តាមប្រព័ន្ធអេឡិចត្រូនិក(e-Payment) នៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) រវាងអគ្គនាយកដ្ឋានរតនាគារជាតិនិងធនាគារពាណិជ្ជដៃគូចំនួន២ (ធនាគារកាណាឌីយ៉ា និង ធនាគារអេស៊ីលីដា)។

៣១-បានចូលរួមប្រជុំក្រុមការងារសិក្សា និងរៀបចំឯកសារគោល (Blueprint) ស្តីពីការកែទម្រង់ប្រព័ន្ធចំណូលមិនមែនសារពើពន្ធ។

៣២-បានចូលរួមធ្វើបទបង្ហាញ ស្តីពីការពង្រឹងកិច្ចបញ្ជិកាគណនេយ្យនៅក្នុងប្រព័ន្ធ FMIS ដើម្បីធានាគុណភាព នៃ របាយការណ៍ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ស្របតាមប្រព័ន្ធគណនេយ្យសាធារណៈ មូលដ្ឋានសាច់ប្រាក់ជូនគណនេយ្យករសាធារណៈ របស់អគ្គនាយកដ្ឋានរតនាគារជាតិ។

៣៣-បានចូលរួមកិច្ចប្រជុំពិភាក្សា អំពីការរៀបចំនិងចូលរួមសិក្ខាសាលាផ្សព្វផ្សាយសារាចរណែនាំ ស្តីពីនីតិវិធីកត់ត្រា និងកិច្ចបញ្ជិកានៃការអនុវត្តចំណូលសេវា របស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តនិងចំណូលសេវាដែលផ្តល់នៅមន្ទីរជំនាញរាជធានី ខេត្ត។

៣៤-បានរៀបចំសារាចរលេខ០១១ សហវ ចុះថ្ងៃទី១០ វិច្ឆិកា ២០២០ ស្តីពីការកំណត់លក្ខខណ្ឌនៃការបង្គត់ចំនួនគត់ខ្ទង់រាយសម្រាប់ទឹកប្រាក់ជារៀល និងការបង្គត់ចំនួនទសភាគខ្ទង់ភាគរយសម្រាប់ទឹកប្រាក់ជាដុល្លារអាមេរិក។

៣៥-បានរៀបចំសារាចរលេខ០១០ សហវ ចុះថ្ងៃទី១០ វិច្ឆិកា ២០២០ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) សម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធ ជំហានទី១។

៣៦-បានរៀបចំសេចក្តីជូនដំណឹងលេខ០៣០ សហវ, ចុះថ្ងៃទី១០ វិច្ឆិកា ២០២០ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិច (e-Payment) សម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធ ជំហានទី១ ទៅធនាគារដៃគូទាំងពីរ (ធនាគារកាណាឌីយ៉ា និង ធនាគារអេស៊ីលីដា)។

៣៧-បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ និងប្រមូលធាតុចូលសម្រាប់រៀបចំស្ថិតិចំណាយ តាមចំណាត់ថ្នាក់មុខងារក្នុងប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS)។

៣៨-បានចូលរួមសិក្ខាសាលាស្តីពីការគ្រប់គ្រង ការចាត់ចែង និងការរឹបអូស ផលនៃបទល្មើសនៅអង្គភាពប្រឆាំងអំពើពុករលួយ។

៣៩-បានចូលរួមកិច្ចប្រជុំពិភាក្សាតាមអនឡាញ អំពីការកែសម្រួលចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាចំណូលថវិកា របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សម្រាប់ប្រើប្រាស់ចាប់ពីឆ្នាំ២០២១។

៤០-បានចូលរួមកិច្ចប្រជុំ ពិនិត្យលើសេចក្តីព្រាងប្រកាស ស្តីពីការបង្កើតបន្ថែមគណនី និងអនុគណនីនៃមាតិកាថវិកា និងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

៤១-បានចូលរួមកិច្ចប្រជុំពិភាក្សាលើអនុសាសន៍នៃរបកគំហើញពីបេសកកម្មត្រួតពិនិត្យ FMIS លើកទី៣ របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ពាក់ព័ន្ធនឹងការប្រើប្រាស់ FMIS សម្រាប់គម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍។

៤២-បានបញ្ចប់សេចក្តីណែនាំបិទបញ្ជីការិយបរិច្ឆេទ២០១៩ និងទិសដៅឆ្នាំ២០២០ របស់រដ្ឋបាលថ្នាក់ជាតិនិង រដ្ឋបាលថ្នាក់ក្រោមជាតិ។

៤៣-បានរៀបចំប្រកាសបំពេញបន្ថែមគណនី អនុគណនីក្នុងប្លង់គណនេយ្យសាធារណៈ និងចំណាត់ថ្នាក់សេដ្ឋកិច្ច មាតិកាថវិកា។

៤៤-បានរៀបចំសេចក្តីណែនាំបិទបញ្ជីរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលឆ្នាំ២០១៩ និងសារាចរណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យឆ្នាំ២០២០ របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

៤៥-បានចូលរួមប្រជុំបច្ចេកទេសជាមួយជំនាញការ នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុបារាំង លើប្រព័ន្ធថវិកា និងអនុក្រឹត្យលេខ៨២ថ្មី។

៤៦-បានចូលរួមពិនិត្យសេចក្តីព្រាងអនុក្រឹត្យថ្មី ជំនួសអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ។

៤៧-បានចូលរួមកិច្ចប្រជុំជាមួយក្រុមការងារបច្ចេកទេសរៀបចំធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រងសហគ្រាសសាធារណៈ ដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងភាគកម្មសាធារណៈ។

៤៨-បានរៀបចំប្រកាសបង្កើតបន្ថែមគណនី និងអនុគណនីចំនួន៧ នៃប្លង់គណនេយ្យសាធារណៈ។

៤៩-បានរៀបចំសេចក្តីណែនាំបិទបញ្ជីគណនេយ្យថវិកា របស់គ្រឹះស្ថានសាធារណៈរដ្ឋបាលឆ្នាំ២០១៩ និងទិសដៅឆ្នាំ២០២០។

៥០-បានជួបជុំជាមួយតំណាងក្រសួងបរិស្ថាន, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, នាយកដ្ឋានចំណូលថវិកា អំពីអាណត្តិឧបត្ថម្ភ នៅឃុំ សង្កាត់ចំនួន៧១ អំពីការអប់រំផ្សព្វផ្សាយដល់តំបន់ការពារធម្មជាតិ។

៥១-បានពិនិត្យរួមគ្នាអនុស្សរណៈ នៃការយោគយល់គ្នា ស្តីពីការប្រើប្រាស់ប្រព័ន្ធផ្ទេរប្រាក់អេឡិចត្រូនិច (E Fund Transfer) ជាមួយធនាគារកាណាឌីយ៉ា។

៥២-បានរៀបចំលិខិតគោរពសុំគោលការណ៍ឯកភាព ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីអំពីការកត់ត្រាបន្ថយពីគណនីប្រាក់បញ្ញើរបស់អគ្គិសនីកម្ពុជាសម្រាប់សងការប្រាក់ ប្រាក់ដើម ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះគម្រោងថ្មីៗ។

៥៣-បានរៀបចំសេចក្តីព្រាងដំបូងនៃអនុក្រឹត្យ ស្តីពីនីតិវិធីនៃការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ និងបានបកប្រែជាភាសាអង់គ្លេស និងបានដាក់ជូនទៅក្រុមជំនាញការបារាំង នៅទីក្រុងប៉ារីស ដើម្បីពិនិត្យ និងផ្តល់យោបល់បន្ថែមទៀត។

៥៤-បានប្រជុំជាមួយធនាគារ J Trust Royal ដើម្បីស្វែងយល់ពីយុទ្ធសាស្ត្រទូទៅ និងសកម្មភាពរបស់ធនាគារ ក្រោយអនុស្សរណៈបានចូលជាធរមានកាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧។

៥៥-បានបកប្រែប្រកាសលេខ ១២១២ ស្តីពីប្លង់គណនេយ្យសាធារណៈជាភាសាអង់គ្លេស សម្រាប់ត្រៀមធ្វើការជាមួយក្រុមជំនាញការបរទេស។

៥៦-បានរៀបចំរបាយការណ៍ ស្តីពីកិច្ចប្រជុំជាមួយក្រសួង រ៉ែ និងថាមពល ពាក់ព័ន្ធនឹងគណនី Social development fund នៅធនាគារជាតិ នៃកម្ពុជា។

៥៧-បានរៀបចំលិខិតលេខ ៣៦៥៩ អ.រតន ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ ស្នើសុំគោលការណ៍អនុញ្ញាត ប្រើប្រាស់សមតុល្យគណនីប្រាក់បញ្ញើរបស់សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណរដ្ឋបាល, ក្រុមហ៊ុនដើម្បីបំពេញ កាតព្វកិច្ចបង់ពន្ធជូនអគ្គនាយកដ្ឋានពន្ធដារ។

៥៨-បានរៀបចំលិខិតលេខ ៣៨៧៦ អ.រតន ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ ជូនអគ្គនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល ស្តីពីកាស្នើសុំរបាយការណ៍បំណុលប្រាក់ខ្ចីក្រៅប្រទេស និងប្រាក់ឱ្យខ្ចីជាប្រចាំខែ ជូននាយកដ្ឋានព័ត៌មានវិទ្យា ដើម្បីធ្វើសន្ទានកម្មរវាង DMFAS ទៅ FMIS។

៥៩-បានរៀបចំលិខិតលេខ ៤១០៤ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ជូនអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ស្តីពីការផ្តល់របាយការណ៍។

៦០-បានចូលរួមប្រជុំរៀបចំអនុក្រឹតបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្មី ចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានឈ្មោះថា "មជ្ឈមណ្ឌលធុរៈកិច្ចថ្មីតេជោ"។

៦១-បានចូលរួមប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងយុទ្ធសាស្ត្រ ស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈ កម្ពុជាមូលដ្ឋានបង្គរ ឆ្នាំ២០១៩-២០៣១ ជាមួយក្រុមប្រឹក្សាជាតិគណនេយ្យ។

៦២-បានរៀបចំកិច្ចប្រជុំចំនួន២លើកពិនិត្យនិងរិះរកវិធានការដោះស្រាយលើបញ្ហាប្រឈម នៃការអនុវត្តប្រកាស អន្តរក្រសួង លេខ ១៨២ សហវ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីលក្ខណ្ឌហិរញ្ញវត្ថុ លក្ខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខណ្ឌទៅឱ្យរដ្ឋបាលរាជធានី ខេត្ត សម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល។

៦៣-បានចូលរួមប្រជុំពិនិត្យសេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធី នៃការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ ដែលជំនួសអនុក្រឹត្យ លេខ ៨២ អនក្រ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

៦៤-បានកែសម្រួលសារាចរលេខ០០២ សហវ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីកិច្ចបញ្ជិកាគណនេយ្យរដ្ឋទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

៦៥-បានរៀបចំកិច្ចប្រជុំណែនាំការបិទបញ្ជីគណនេយ្យឆ្នាំ២០២០និងទិសដៅឆ្នាំ២០២១ ដល់គណនេយ្យកររដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករបុរេប្រទាន។

៦៦-រៀបចំសារាចរណែនាំ ស្តីពីកិច្ចបញ្ជិកាគណនេយ្យរបស់រតនាគារខេត្តបាត់ដំបង រដ្ឋបាលក្រុង ស្រុក លើថវិកា ផ្ទេរមុខងារការអប់រំកុមារតូច បឋម និងក្រៅប្រព័ន្ធ។

៦៧-បានជួបប្រជុំជាមួយតំណាងធនាគារ ជីប ម៉ុង ពាក់ព័ន្ធនឹងការត្រៀមចុះអនុស្សារណៈបំរើសេវាប្រមូលចំណូល និងចំណាយជាមួយរដ្ឋ។

៦៨-ក្រុមការងារអធិការកិច្ចរតនាគារ បានចុះពិនិត្យកិច្ចបញ្ជិកាគណនេយ្យសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៩ និងបណ្តាឆ្នាំពាក់ព័ន្ធនៅគ្រប់រតនាគាររាជធានី ខេត្តទូទាំងប្រទេស។

៦៩-ក្រុមការងារអធិការកិច្ចរតនាគារ បានចុះពិនិត្យផ្ទៀងផ្ទាត់បញ្ជី និងផ្ទេរភារកិច្ចជូនប្រធានរតនាគារខេត្តព្រះសីហនុថ្មី ជំនួសប្រធានរតនាគារចាស់ដែលចូលនិវត្តន៍។

៧០-ក្រុមការងារអធិការកិច្ចរតនាគារ បានចុះពិនិត្យផ្ទៀងផ្ទាត់បញ្ជី និងផ្ទេរភារកិច្ចជូនប្រធានរតនាគារខេត្តឧត្តរមានជ័យថ្មី ជំនួសប្រធានរតនាគារចាស់ដែលផ្លាស់ចេញ។

**II-<u>ទិសដៅសម្រាប់អនុវត្តការងារឆ្នាំ២០២១÷</u>**

អគ្គនាយកដ្ឋានរតនាគារជាតិមានទិសដៅសម្រាប់អនុវត្តការងារឆ្នាំ២០២១ មានដូចខាងក្រោម÷

១-ត្រូវបន្តជំរុញលើការបើកផ្តល់ប្រាក់បៀវត្សពីរសប្តាហ៍ម្តងក្នុងមួយខែ ជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធឱ្យបានទាន់ពេលវេលា។

២-ព្រាងសេចក្តីប្រកាស ស្តីពីនីតិវិធីចំណាយរដ្ឋទេយ្យសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសារាចរស្តីពីកិច្ចប្រតិបត្តិការចំណាយថវិការដ្ឋបាលក្រុង ស្រុកក៏បានរៀបចំរួចរាល់ ប៉ុន្តែត្រូវបានសម្រេចពន្យាពេលអនុវត្តទៅឆ្នាំ២០២២វិញ ដើម្បីឱ្យមានភាពសមស្របជាមួយនឹងច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងអនុក្រឹត៨១-៨២ ដែលកំពុងរៀបចំថ្មីមិនទាន់រួចរាល់។

៣-បន្តជំរុញការងាររៀបចំឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានថ្នាក់ជាតិសម្រាប់ឆ្នាំថវិកា២០២១ ឱ្យបានត្រឹមត្រូវនិងទាន់ពេលវេលា។

៤-បន្តសហការជាមួយក្រុមការងារ ITD ដើម្បីរៀបចំរបាយការណ៍ចំណាយថវិកា ចេញពីប្រព័ន្ធ FMIS ជាពិសេសរបាយការណ៍សម្រាប់បម្រើដល់ការរៀបចំសេចក្តីព្រាងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ។

៥-ត្រៀមរៀបចំអនុវត្តប្រព័ន្ធ NRMIS នៅអង្គភាពច្រកចេញចូលតែមួយ នៅរដ្ឋបាលរាជធានីភ្នំពេញ។

៦-បន្តពិនិត្យតាមដាន និងកែលម្អពីការធ្វើសន្ធានកម្មពី NRMIS ទៅប្រព័ន្ធ FMIS។

៧-បន្តពិនិត្យ MoU ជាមួយធនាគារពាណិជ្ជដៃគូ។

៨-បន្តកិច្ចប្រជុំជាមួយមន្ត្រីបច្ចេកទេសប្រព័ន្ធគ្រប់គ្រងទិន្នន័យ នៅអង្គភាពច្រកចេញចូលតែមួយ ដើម្បីពិភាក្សា អំពីដំណើរការរៀបចំដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ (NRMIS) នៅសាលារាជធានី ខេត្ត។

៩-រៀបចំលិខិតក្នុងនាមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំណត់ពេលវេលាតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលផ្តល់របាយការណ៍គណនេយ្យ, របាយការណ៍ថវិកា។

១០-សិក្សាកែតម្រូវប្លង់បណ្ណផ្ទេរភារៈចំណាយ ក្នុងការផ្ទេរវិភាជន៍ថវិការបស់ឃុំ សង្កាត់ ក្រុង ស្រុកទៅប្រើទំរង់ ឯកសារផ្សេងៗ។

១១-អធិការកិច្ចរតនាគារ ត្រូវចុះត្រួតពិនិត្យការងាររតនាគាររាជធានី ខេត្ត សម្រាប់ការិយបរិច្ឆេទ២០២០ និងបណ្តាឆ្នាំពាក់ព័ន្ធជាបន្តបន្ទាប់ទៀត។